# ព្រះរាជក្រម

នស/រកម/១១១៧/០១៤

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

រដ្ឋសភា
ចូល លេខ ៣៣៥១
ថ្ងៃទី ២៤/១១ ឆ្នាំ ២០១៧ ម៉ោង
បញ្ជូនទៅ

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីឧបាស្រ័យពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

# ស្តីពី

# ឧបាស្រ័យពាណិជ្ជកម្ម

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.**_គោលបំណង

ច្បាប់នេះមានគោលបំណងការពារនិងដោះស្រាយផលប៉ះពាល់ជាអវិជ្ជមានចំពោះឧស្សាហកម្ម កម្ពុជាបណ្តាលមកពីការធ្វើពាណិជ្ជកម្មនាំចូលដោយមិនស្មោះត្រង់និងការនាំចូលដោយគំហុក ដោយប្រើប្រាស់វិធានការឧបាស្រ័យពាណិជ្ជកម្ម អនុលោមតាមកិច្ចព្រមព្រៀងពាក់ព័ន្ធរបស់អង្គការពាណិជ្ជកម្មពិភពលោក ។

**មាត្រា ២ .**_គោលដៅ

ច្បាប់នេះមានគោលដៅកំណត់អំពីគោលការណ៍ យន្តការ នីតិវិធី និងវិធានទាក់ទងនឹងឧបាស្រ័យពាណិជ្ជកម្ម។

**មាត្រា ៣ .**_វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការលក់បង្ខូចថ្លៃ ការឧបត្ថម្ភធននិងវិធានការពន្ធប៉ះប៉ូវ និងវិធានការ ការពារទាក់ទងនឹងការធ្វើពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា អនុលោមតាមកិច្ចព្រមព្រៀងពាក់ព័ន្ធរបស់អង្គការពាណិជ្ជកម្មពិភពលោក ។

**មាត្រា ៤ .**_និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

# ជំពូកទី ២
# គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម

**មាត្រា ៥ .**_គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម

ត្រូវបានបង្កើតគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីបំពេញភារកិច្ចនានាពាក់ព័ន្ធនឹងឧបាស្រ័យពាណិជ្ជកម្ម ស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៣
# នីតិវិធីឧបាស្រ័យពាណិជ្ជកម្ម

## ផ្នែកទី ១
## វិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ

**មាត្រា ៦ .**–អត្តសញ្ញាណកម្មនៃការលក់បង្ខូចថ្លៃ

ផលិតផលទាំងឡាយណាដែលស្ថិតក្រោមការស៊ើបអង្កេត ហើយកំពុងចរាចរក្នុងគោលដៅពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយលក់ក្នុងថ្លៃដែលទាបជាងតម្លៃធម្មតានៅក្នុងប្រទេសប្រភពដើម ត្រូវចាត់ទុកថាជាផលិតផលដែលលក់បង្ខូចថ្លៃ ។

**មាត្រា ៧ .**–តម្លៃធម្មតាផ្អែកលើថ្លៃនៅក្នុងប្រទេសនាំចេញ ឬប្រទេសប្រភពដើម

គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់តម្លៃធម្មតានៃផលិតផលក្រោមការស៊ើបអង្កេត ដោយផ្អែកលើមូលដ្ឋានថ្លៃប្រៀបធៀបដែលបានបង់ ឬដែលត្រូវបង់ក្នុងការធ្វើពាណិជ្ជកម្មធម្មតាសម្រាប់ការលក់ផលិតផលដូចគ្នានោះដល់ដៃអ្នកប្រើប្រាស់នៅក្នុងប្រទេសនាំចេញ ។

**មាត្រា ៨ .**–តម្លៃធម្មតាផ្អែកលើថ្លៃនាំចេញទៅប្រទេសទី ៣ ឬតម្លៃដែលបានកសាង

នៅពេលដែលគ្មានការលក់នូវផលិតផលដូចគ្នានៅក្នុងទីផ្សារក្នុងស្រុកនៃប្រទេសនាំចេញឬនៅពេលដែលមានការលក់ដែរ តែមិនអាចយកជាមូលដ្ឋានមកប្រៀបធៀបបានដោយហេតុផលស្ថានភាពទីផ្សារ ឬដោយសារទំហំនៃការលក់មានកម្រិតតិចតួចក្នុងប្រទេសនាំចេញ នោះគណៈកម្មាធិការ-ជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់តម្លៃធម្មតានៃផលិតផលក្រោមការស៊ើបអង្កេត ផ្អែកលើមូលដ្ឋានណាមួយក្នុងកថាខណ្ឌ (១) ឬ (២) ដូចខាងក្រោម៖

១- ផ្អែកលើថ្លៃប្រៀបធៀបនៃផលិតផលដូចគ្នា នៅពេលនាំចេញពីប្រទេសប្រភពដើមចូលទៅកាន់ប្រទេសទីបី ដែលបង្ហាញថាថ្លៃផលិតផលដូចគ្នានោះអាចជាថ្លៃតំណាងដើម្បីយកធ្វើជាមូលដ្ឋាន ឬ

២- ផ្អែកលើចំណាយផលិតកម្មនៅក្នុងប្រទេសប្រភពដើម បូកនឹងចំណាយរដ្ឋបាលសមស្រប ចំណាយលើការលក់ និងចំណាយផ្សេងៗទៀត រួមទាំងប្រាក់ចំណេញ ។

**មាត្រា ៩ .**–ថ្លៃនាំចេញ

ថ្លៃនាំចេញត្រូវបានកំណត់ដូចខាងក្រោម៖

ក-ថ្លៃនាំចេញ គឺថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដសម្រាប់ផលិតផលក្រោមការស៊ើបអង្កេត នៅពេលដែលបានលក់សម្រាប់នាំចេញពីប្រទេសនាំចេញមកកម្ពុជា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ខ-ក្នុងករណីដែលគ្មានថ្លៃនាំចេញឬនៅពេលដែលគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម យល់ឃើញថា ថ្លៃនាំចេញមិនអាចជឿជាក់បាន ដោយសារការទិញ លក់ទំនិញ ធ្វើឡើងតាមរយៈសមាគមឬជាលក្ខណៈបំពេញខាតរវាងអ្នកនាំចេញនិងអ្នកនាំចូលឬភាគីទីបីណាមួយ ដូច្នេះ៖

១-ថ្លៃនាំចេញអាចត្រូវបង្កើតឡើងលើមូលដ្ឋាននៃថ្លៃដែលផលិតផលនាំចូល ត្រូវបានលក់បន្តលើកដំបូងទៅឲ្យអ្នកទិញឯករាជ្យណាមួយ ឬ

២-គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មអាចកំណត់ថ្លៃនាំចេញ ដោយផ្អែកលមូលដ្ឋានសមស្របណាមួយ ប្រសិនបើផលិតផលមិនទាន់បានលក់បន្តទៅឲ្យអ្នកទិញឯករាជ្យណាមួយ ឬត្រូវបានលក់បន្តដោយបានកែច្នៃខុសពីស្ថានភាពដើមនៅពេលនាំចូល ។

គ-នៅពេលគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម កំណត់តម្លៃធម្មតាដោយផ្អែកលើមូលដ្ឋាននៃប្រទេសប្រភពដើម ថ្លៃនាំចេញត្រូវតែជាថ្លៃដែលបានទូទាត់ ឬនឹងត្រូវទូទាត់ពិតប្រាកដសម្រាប់ផលិតផលក្រោមការស៊ើបអង្កេត នៅពេលលក់សម្រាប់នាំចេញនៅក្នុងប្រទេសប្រភពដើមនោះ ។

**មាត្រា ១០ .**_ការកែតម្រូវតម្លៃធម្មតានិងថ្លៃនាំចេញ

គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវធ្វើការប្រៀបធៀបដោយត្រឹមត្រូវរវាងថ្លៃនាំចេញនិងតម្លៃធម្មតា ។ ការប្រៀបធៀបនេះត្រូវតែធ្វើឡើងនៅទីតាំងដូចគ្នានៃការធ្វើពាណិជ្ជកម្មដែលជាធម្មតាគិតត្រឹមទ្វាររោងចក្រ និងការលក់ក្នុងពេលប្រហាក់ប្រហែលគ្នា។ ការកែតម្រូវសមហេតុផលត្រូវធ្វើឡើងក្នុងករណីមានភាពខុសគ្នា ដែលប៉ះពាល់ដល់ការប្រៀបធៀបតម្លៃ ។

**មាត្រា ១១ .**_កម្រិតនៃការលក់បង្ខូចថ្លៃនីមួយៗ

គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ត្រូវកំណត់កម្រិតនៃការលក់បង្ខូចថ្លៃរបស់អ្នកនាំចេញ ឬផលិតករនីមួយៗដែលពាក់ព័ន្ធនឹងផលិតផលក្រោមការស៊ើបអង្កេត ។ ប៉ុន្តែគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម អាចកម្រិតការត្រួតពិនិត្យ និងលទ្ធផលនៃកម្រិតលក់បង្ខូចថ្លៃនីមួយៗដល់ចំនួនមួយដែលសមហេតុផល ចំពោះភាគីពាក់ព័ន្ធ ឬផលិតផលក្រោមការស៊ើបអង្កេត ។

**មាត្រា ១២ .**_ការកំណត់ការខូចខាត

ការកំណត់ការខូចខាតសម្ភារៈណាមួយ ត្រូវតែធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងវិជ្ជមាន និងត្រូវមានការត្រួតពិនិត្យបែបសត្យានុម័តនូវចំណុចដូចខាងក្រោម ៖

ក- បរិមាណនៃការនាំចូលដោយបង្ខូចថ្លៃ

ខ- ផលប៉ះពាល់នៃការនាំចូលដោយបង្ខូចថ្លៃមកលើថ្លៃនៃផលិតផលដូចគ្នានៅទីផ្សារក្នុងស្រុក និង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL